# បុណ្យបច្ច័យបួន

ពាក្យថា (បច្ច័យ) សំដៅដល់ “គ្រឿងសម្រាប់អាស្រ័យរបស់បព្វជិត” ។អ្វីទៅដែលហៅថា (បច្ច័យ) គ្រឿងអាស្រ័យរបស់បព្វជិត? បើជាទូទៅហៅថា អាមិស ។ អាមិស ជាវត្ថុ សម្ភារៈ ឧបភោគ បរិភោគ ប្រើប្រាស់បម្រើសុខភាព ជួយជាកម្លាំង បម្រើតម្រូវការ សេចក្តីប្រាថ្នាចង់បានរបស់មនុស្សទូទៅ ។
តាមន័យនេះ អាមិស បានដល់វត្ថុគ្រប់យ៉ាង សម្រាប់ទំនុកបម្រុង ឧបត្ថម្ភជីវិតមនុស្សឲ្យរស់នៅបានសុខស្រួល ឈានទៅរុងរឿងថ្លៃថ្លា ។ ដូចជាសំពត់ខោអាវ សំលៀកបំពាក់សម្រាប់បិទបាំង កែលំអរាងកាយ អាហារភោជនគ្រប់ប្រភេទសម្រាប់ហូបពិសា សម្ភារៈ ភស្តុភា បណ្ណាការ ទ្រព្យសម្បត្តិសម្រាប់សំរួលការដេកដើរ អង្គុយ សម្រាកស្នាក់អាស្រ័យនិងថ្នាំកែរោគគ្រប់មុខ ។ ជារូម អ្វី ៗ ជាវត្ថុ សម្ភារៈ របស់របរ ប្រដាប់ប្រដាគ្រឿងបរិភោគ ប្រើប្រាស់របស់មនុស្ស សម្រាប់ជួយផ្តល់ការសុខស្រួលឲ្យកើតជាផលប្រយោជន៍ ផ្គត់ផ្គងជីវិត ប្រមូលផ្តុំវត្ថុរួមទាំងអស់នោះ លោក ហៅជា ពាក្យបច្ចេកទេសតែមួយថា អាមិស ។អាមិស ជាវត្ថុជួយមនុស្សឲ្យរស់នៅបានស្រួល ជួយផ្តល់ផលប្រយោជន៍ឲ្យមនុស្សមានអានុភាព មានអានិសង្សច្រើនសម្រាប់ការរស់នៅ ។
ព្រះពុទ្ធសាសនា ព្រះពុទ្ធអង្គទ្រង់ឆ្វេងយល់ច្បាស់នូវផលប្រយោជន៍នៃអាមិសទើបទ្រង់អនុញ្ញាតឲ្យបព្វជិតបរិភោគ ប្រើប្រាស់អាមិស តាមការគួរ ។ ក្រៅពី បង្សុកុលចីវរ ដើរបិណ្ឌបាត ដេកនៅក្រោមដើមឈើ ផឹកថ្នាំមូតភេសជ្ជៈ ព្រះអង្គអនុញ្ញាតឲ្យប្រើ អតិរេកលាភ បាន ដើម្បីជួយសម្រួលជីវភាពភិក្ខុសង្ឃ ឲ្យប្រព្រឹត្តទៅបានស្រួល ។ តែព្រះអង្គមិនទ្រង់ហៅថា អាមិស ទេ ទ្រង់ហៅថា “បច្ច័យ” ។ ព្រោះបច្ច័យជាគ្រឿងបន្តជីវិតឬជំនួយជីវិតមនុស្សឲ្យប្រព្រឹត្ត ទៅបានស្រួល ។ ពិសេស បច្ច័យអាចផ្តល់ផលប្រយោជន៍ ដ៏សំខាន់ដល់មត្តញ្ញូជន អ្នកស្គាល់ប្រមាណក្នុងការបរិភោគប្រើប្រាស់ ។
មនុស្សយើងបើមិនមានបច្ច័យទាំងអស់ជាជំនួយទេ នឹងរស់នៅពុំបាន ធ្វើប្រយោជន៍អ្វីក៏ពុំកើតដែរ ។

បច្ច័យដ៏ច្រើនសន្ធឹកសន្ធាប់នោះ ប្រមូលមកហៅត្រឹមតែ ៤ បច្ច័យគឺ ចិវរប្បច្ច័យ១ បិណ្ឌបាតប្បច្ច័យ១ សេនាសនប្បច្ច័យ ១ និងគិលានភេសជ្ជប្បច្ច័យ ១ ។
ជាការពិត ការរស់នៅបើមានតែបច្ច័យ៣ ខ្វះបច្ច័យណាមួយក៏រស់នៅមិនស្រួល ។

១. សំពត់ខោអាវសារសៃ្ប ជាសម្លៀកបំពាក់ គ្រឿងសម្លៀកដណ្តប់បិទបាំងរាងកាយ ការពារ កេរ្តិ៍ខ្មាស់ជាដើម មានស្បង់ ចីពរ សង្ឃាដី និងបរិក្ខាបន្ទាប់បន្សំ ដូចអង្សាក់វត្ថពន្ធកាយពន្ធនិសីទនៈ សាដក កន្សែង .....ជាដើមរាប់បញ្ចូលជាចីវរប្បច្ច័យ
២. គ្រឿងបរិភោគ ហូប ពិសា ឆាន់ មានអាហារភោជន នំនែក បង្អែម ចំអាបបាយ សម្ល ត្រី សាច់ ប្រហុក ផ្អក អំបិល ... ជាដើម រាប់បញ្ចូលជាបិណ្ឌបាតប្បច្ច័យ ។
៣. ទីលំនៅភូមិស្ថានសម្រាប់ជ្រកកោន ដេកអង្គុយ ស្នាក់អាស្រ័យ ថ្ងៃយប់មានផ្ទះសម្បែង កុដិ សាលា កន្ទេល ខ្នើយ វិហារ គ្រែ តុ ទូ កៅអី ផ្ទាំងចាន ស្លាបព្រា បាត្រ...ជាដើម រាប់បញ្ចូលហៅថាសេនាសនប្បច្ច័យ ។
៤.ថ្នាំសង្កូវ កែរោគ ការពារ ព្យាបាលជម្ងឺដម្កាត់ផ្សេង ៗ មាន ថ្នាំបុរាណ ឱសថសម័យ សម្រាប់ផឹកលាប ចាក់ ភេសជ្ជៈ ៥ មុខជាដើម មានទឹកដោះរាវ ទឹកដោះខាប់ ប្រេងស្គ ទឹកឃ្មុំ និងទឹកអជ្ជបានជាដើម រាប់បញ្ចូលហៅថាគិលានភេសជ្ជប្បច្ច័យ ។
ប៉ុន្តែ បច្ច័យគ្រប់យ៉ាងដែលរាប់បញ្ចូលតាមឈ្មោះតែ ៤ បច្ច័យនេះ ជាបច្ច័យ(អាមិសវត្ថុ) សម្រាប់មនុស្សទូទៅ ចំពោះបព្វជិតក្នុងពុទ្ធសាសនា ព្រះអង្គទ្រង់អនុញ្ញាតឲ្យបរិភោគប្រើប្រាស់បច្ច័យ ដែលជាគ្រឿងអាស្រ័យរបស់បព្វជិតនោះដោយមានកំណត់” ។

ម្យ៉ាងទៀត បច្ច័យ ៤ ដែលមានកំណត់នោះ
បព្វជិតមុននឹងបរិភោគប្រើប្រាស់នូវបច្ច័យណាមួយ ដែលទ្រង់បានអនុញ្ញាត សុទ្ធតែត្រូវពិចារណាដោយសតិសម្បជញ្ញៈសិន សឹមបរិភោគប្រើប្រាស់ ។
ការរៀបរាប់ដោយសង្ខេបមកប៉ុណ្ណេះឯង
ដែលនឹងឆ្លើយតបទៅនឹងសំណួរដែលសួរខាងដើមថា “អ្វីទៅដែលហៅថា បច្ច័យ គ្រឿងអាស្រ័យរបស់បព្វជិតនោះឯង “ ។
ពាក្យថា “បុណ្យបច្ច័យបួន” គឺជាឈ្មោះ បុញ្ញកម្ម
មួយបែបដែលបូរាណាចារ្យខ្មែរយើងបានសន្មតហៅ តាមបច្ច័យទេយ្យវត្ថុដែលគេធ្វើទាន ដោយរៀបខ្ចប់បច្ច័យទាំងបួនមុខ ក្នុងមួយកញ្ចប់ ៗសម្រាប់ជាទេយ្យទាន
។តើបុណ្យបច្ច័យបួន ទាយកទាយិកា ត្រូវធ្វើដូចម្តេច ?
មុននឹងធ្វើបុណ្យលោកអ្នកម្ចាស់ដើមបុណ្យ ឬម្ចាស់ដើមទានប្រធានបុណ្យ តែងប្រជុំពិភាក្សាគ្នា ថា តើត្រូវនិមន្តលោកប៉ុន្មានអង្គ ? និមន្តលោក ១អង្គ ២អង្គ -៣ឬ៤អង្គឬ៥-៦-៧អង្គ ។លោកអ្នកអាចនិមន្តលោកមកទទួលក្នុងបុណ្យប៉ុន្មានអង្គក៏បាន អាស្រ័យ បសាទសទ្ធា និងលទ្ធភាពរបស់ទាយកទាយិកាម្ចាស់បុណ្យ ។
បើយើងតម្រូវនិមន្តលោក ២អង្គ យើងរៀបទេយ្យវត្ថុ ២កញ្ចប់ និមន្ត ៣អង្គរៀបទេយ្យវត្ថុ៣កញ្ចប់ និមន្ត ៤អង្គ រៀប ៤កញ្ចប់ បើមានសទ្ធានិមន្ត ៧អង្គគប្បីរៀបទេយ្យវត្ថុ ៧ កញ្ចប់ គឺត្រូវរៀបទេយ្យវត្ថុជាកញ្ចប់ ៗ

តាមជំនួនលោកដែលត្រូវនិមន្តមកនោះ ឲ្យបានមួយកញ្ចប់ ១អង្គគ្រប់ៗ អង្គ
។ឯទេយ្យវត្ថុក្នុងមួយកញ្ចប់ ៗ ត្រូវមានបច្ច័យ បួនមុខគឺ ចីវរ បិណ្ឌបាតសេនាសនៈ ភេសជ្ជៈ
ដាក់ចូលទៅក្នុងមួយកញ្ចប់ ៗ ដូច ៗ គ្នា ។
មានអ្នកខ្លះយល់ច្រឡំថា ធ្វើបុណ្យបច្ច័យបួន
គេនិមន្តលោកតែបួនអង្គទេបើនិមន្តលោកទៅដល់ ៥អង្គ វាទៅជាបុណ្យបច្ច័យប្រាំហើយ
?ការយល់យ៉ាងនេះ មុខគួរឲ្យសង្វេគបែជាយកព្រះសង្ឃធ្វើជាបច្ច័យទៅ
វិញពុទ្ធោអើយ ! បច្ច័យមានតែបួនប្រភេទទេ មានបច្ច័យឯណាទៅដល់ប្រាំ
ឬក៏ប្រាំមួយមុខនោះ ! ការធ្វើបុណ្យបច្ច័យបួនគឺ
គេរៀបទេយ្យវត្ថុឲ្យមានគ្រប់ទាំងបួនបច្ច័យក្នុងមួយកញ្ចប់ ។ បើម្ចាស់
បុណ្យជាអ្នកមានធូរធារគេអាចបញ្ចូលចីវរប្បច្ច័យ ២ មានស្បង់ផងកន្សែងផង ។
បិណ្ឌបាតប្ប័យ ៣ឬ៥ មានអង្ករផង ត្រីងៀតផង ។ ទឹកត្រីផងសេនាសនប្បច្ច័យ ៣ឬ៥
មានកន្ទេលផងខ្នើយផង ស្បែកជើងឬប៉ានពែងផងក៏បាន និងគិលានភេសជ្ជប្បច្ច័យ ៣-៥
មានទឹកដោះគោ តែស្ករ ឬថ្នាំពេទ្យថែមទៀតផងក៏បាន។ រួមបច្ច័យទាំងបួន
ដ៏ច្រើនមុខនេះបញ្ចូលគ្នា វេចខ្ចប់ជាមួយកញ្ចប់ ។
ទេយ្យវត្ថុដ៏ច្រើនមុខនេះក៏ឈ្មោះថា បច្ច័យបួន ។
យើងរៀបកញ្ចប់សម្រាប់តែលោកមួយអង្គក៏បច្ច័យបួន រៀប ៥-៥-៦ កញ្ចប់សម្រាបលោក
៥-៥-៦អង្គក៏ឈ្មោះថា “ធ្វើបច្ច័យបួនដែរ ។
គ្រាប់តែថា ប្រើធ្វើតូចបច្ច័យទាំងបួន មួយកញ្ចប់ ៗ ក៏តិច ។ ទោះបីតិចក្ដីច្រើនក្ដី
ក៏ត្រូវឲ្យបាន៥ មុខ ។ឯវិធីធ្វើ ដូចជាបុណ្យផ្សេងដែរ គឺថ្ងៃបុណ្យនោះ
ពេលព្រឹកបងប្អូនជិតខាង
ជួយធ្វើរោងបុណ្យមុខផ្ទះ តុបតែងរោង ហើយយករណ្ដាប់ទេយ្យវត្ថុ
ដែលកញ្ចប់ដោយក្រដាស់ភ្លឺស្អាតចំនួន
ប៉ុន្មានកញ្ចប់ដែលយើងតម្រូវនិមន្តព្រះសង្ឃប៉ុន្មានអង្គនោះ
មកដាក់តម្រៀបលើគ្រែក្បែរគ្រឿងសក្ការៈព្រះពុទ្ធរូប ។ ដល់ពេលរសៀល
មេក្រូបុណ្យបន្លឺសម្លេង ជាពេលដែលភ្ញៀវអញ្ជើញទៅចូលបុណ្យ ។
ពេលល្ងាចលោកអាចារ្យ ចាប់ផ្ដើមនមស្ការថ្វាយបង្គំ ហើយនិមន្តព្រះសង្ឃតាមចំនួនមក
រួចសមាទានសីលនិងអារាធនាចម្រើនព្រះបរិត្ត ។ បើមានទេសនាផង ក៏រៀបធម្មាសនៈ
ហើយនិមន្តព្រះធម្មកថិក សម្ដែងធម៌ទេសនាតទៅ ។
លុះព្រឹកឡើងនិមន្តព្រះសង្ឃទទួលយាគូ ។ បើមិនបានធ្វើយាគូទេ ធ្វើសង្ឃភត្តតែម្ដងនោះ
គប្បីសមាទានសីល ហើយអ្នកដើមបុណ្យព្រមទាំងកូនចៅ
ញាតិមិត្តនាំគ្នាកាន់គ្រឿងប្រដាប់ ទេយ្យវត្ថុឡើង ដើម្បីវេរទេយ្យវត្ថុ បច្ច័យ ៥
នេះនិងវេរចង្ហាន់ទៅជាមួយគ្នា ។

លោកអាចារ្យនាំពុទ្ធបរិស័ទវេរ ៖ នមោ ៣ចប់ (តាមទម្លាប់
រួចអ្នកដើមបុណ្យទាំងអស់និងពុទ្ធបរិស័ទ ថាតាមលោកអាចារ្យវេរ ៖
មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេសង្ឃោ ឥមេ ចត្តារោ
បច្ចយេ បដិគណ្ហាតុ (មាតាបិតាទីនំ គុណវន្តានញ្ច)
អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។
ទុតិយម្បិ . មយំ ភន្តេ ........
តតិយម្បិ . មយំ ភន្តេ ...........
បពិត្រព្រះសង្ឃដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយបាននាំមកនូវបច្ច័យទាំង
ឡាយ ៤នេះ មកដម្កល់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រ
ព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក នូវបច្ច័យទាំងឡាយ ៤នេះ
ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចសុខ
(ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង អស់កាលជា
អង្វែងទៅហោង ។
អស់វារៈពីរដងផង ....។ អស់វារៈបីដងផង...។

បន្ទាប់មកចូលទៅអង្គុយឲ្យជាប់ហត្ថបាស ហើយប្រគេនទេយ្យវត្ថុនិងចង្ហាន់ដល់ព្រះសង្ឃ
។ ព្រះសង្ឃ អនុមោទនា (គឺសូត្រធម៌) ចប់ហើយ យើងសូត្រឧទ្ទិសកុសលផលទាន
តាមទម្លាប់ ។
សូមបញ្ជាក់ថា ៖ ការវេរនេះ បើមានតែទេយ្យវត្ថុក៏វេរយ៉ាងនេះ ។ បើមានចង្ហាន់
ព្រះសង្ឃឆាន់នៅផ្ទះបុណ្យឬ រាប់បាត្រ ចង្ហាន់ដាក់ចានស្រាក់យកទៅឆាន់នៅឯវត្តផង
ក៏វេរតែមួយលើកដូចខាងលើនេះជាការស្រេច ។តែបើលោកអាចារ្យចង់វេរដោយឡែក
ជាពីរវគ្គ គឺ វេរទេយ្យវត្ថុ បច្ច័យ៤ដូចខាងលើ រួចហើយសឹមវេរចង្ហាន់ មួយលើកទៀត
ដោយឡែកពីបាលី
ខាងលើនេះ ក៏បានគឺ វេរ ៖
Ø អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បទិតោ .............។ល។
Ø មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សជ្ជេត្វា សង្ឃស្ស ទេម ..........។ល។

ប៉ុន្តែ សូមលោកអាចារ្យ មើលពេលវេលាផង ព្រោះតែគេហៅថា
(លោកអាចារ្យអ្នកនាំគេនោះ) ត្រូវស្វែងយល់ឲ្យសព្វគឺ ៖ កាលញ្ញូ គួរដឹង-ស្គាល់កាលវេលា
(ក្រែងយូរពេកទៅនាំសៅហ្មង) បរិសញ្ញូ គួរដឹងស្គាល់បរិស័ទជុំវិញខ្លួន
(ក្រែងមានអ្នកសំដែងអាកប្បកិរិយា ទឹកមុខធុញទ្រាន់) ។ព្រោះថា បញ្ហាចង្ហាន់
សំខាន់នៅលើការប្រគេន ទទួលតាមផ្លូវកាយទើបព្រះ
សង្ឃទទួលឆាន់បាន មិនសំខាន់ពេកលើការវេរដោយវាចា ហើយមិនប្រគេនដោយកាយ
លោកមិនអាចឆាន់ដោយដាច់ខាត ។ (នេះជាវិន័យបញ្ញត្តិ) ។

ម្យ៉ាងទៀត ទម្លាប់កន្លែងមួយចំនួន កាលលោកសូត្រមន្តនៅថ្ងៃរសៀល ល្ងាចឬពេលយប់ចប់ហើយ គេវេរទេយ្យវត្ថុប្រគេនលោកតែម្តង ប៉ុន្តែលោកឯាចារ្យ ខ្លះថា ការវេរប្រគេនយ៉ាងនេះមិនបានទេ ព្រោះក្នុងបច្ច័យទាំងបួននោះមានបិណ្ឌបាតបច្ច័យផង វេរប្រគេនខុសកាលមិនកើត គឺផុតពីថ្ងៃត្រង់ ហើយ ជាវេលាវិកាល ។

ត្រង់ចំណុចនេះសូមយល់ថា បើក្នុងកញ្ចប់ទេយ្យវត្ថុបច្ច័យបួននោះ មានវត្ថុបិណ្ឌបាតពិតៗ ដូចជា អង្ករ ត្រី សាច់ ប្រហុក អំបិល ទឹកត្រី ។ល។ យ៉ាងនេះនឹងវេរប្រគេនក្នុងវេលាខុសកាល ក៏ពិតជាមិនគួរមែន ដូច្នេះ គួរត្រឹមតែបវរណា ហើយព្រឹកឡើងសឹមប្រគេន ។ ប៉ុន្តែ បើក្នុងកញ្ចប់ទេយ្យវត្ថុមានសំភារៈបរិក្ខាបីបច្ច័យ រួចយកថវិកាដាក់ស៊ងបញ្ចូលជំនួស បិណ្ឌបាតបច្ច័យបន្ថែមចូលទៅក្នុងកញ្ចប់នោះការវេរជាបច្ច័យបួនបាន ហើយវេរប្រគេនពេលណាក៏បាន ។បច្ចុប្បន្ននេះ ស្ទើរគ្រប់កន្លែងក្នុងកម្ពុជាយើង កាលណាគេធ្វើបុណ្យបច្ច័យបួន គេរៀបចំរណ្តាប់អង្គ ទេយ្យវត្ថុក្នុងមួយកញ្ចប់ ៗ ដែលសម្បូណ៌បែបឃើញមានត្រឹមតែ ៣បច្ច័យគឺ សាដក ឬស្បង់ ចីពរ និងមានសាប៊ូប្រាស់ថ្នាំដុសធ្មេញ ប្រេងក្រូឡា ថ្នាំពេទ្យ ទឹកដោះគោ តែស្ករ កាហ្វេ ទឹកក្រូច ប៉ាន តែវ ស្បែកជើង ចាន ស្លាបព្រា ភួយមុង និងមាននៅអែបក្រៅកញ្ចប់និមួយ ៗ ជូនកាល អាចមាន ចានស្រាក់ កំសៀវ ចង្ក្រាន កន្ទេល ខ្នើយ ។ល។ រាប់មកប៉ុណ្ណេះសុទ្ធតែបច្ច័យ ៣ ពុំទាន់មានបិណ្ឌបាតប្បច្ច័យឡើយ ហើយបិណ្ឌបាតប្បច្ច័យ សុទ្ធ ៗ ជាអង្ករ ត្រី សាច់ ពុំដែលឃើញគេដាក់ បញ្ចូលក្នុងជាមួយបច្ច័យទាំង ៣ ក្នុងកញ្ចប់នោះឡើយ ប៉ុន្តែ គេនិយមដាប់ថវិកាគឺ ប្រាក់កាស ពីរបី ពាន់ ប្រាំពាន់ មួយហ្មឺនរៀលក្នុងមួយកញ្ចប់ ៗ តាមលទ្ធភាព ។ ប្រាក់នេះក៏សម្រាប់បច្ច័យ ៤ពិត ដូច្នេះវេរជាបច្ច័យ ៤ បានហើយ គឺទេយ្យវត្ថុ ក្នុង មួយកញ្ចប់ ៗ សម្រាប់អង្គនោះពិតជាបច្ច័យបួនដោយត្រឹមត្រូវ ថែមទាំងអាចារ្យវេរប្រគេន ពេលណាក៏បានឥតមានទាស់ ។

## សូមអស់លោកអ្នកអនុមោទនា !

ចប់